# ដកចិត្តចេញពីកាយ

| | |
|---|---|
| រូបកាយទាំងឡាយនៃយើងគេ | ជាសង្ខារទេ នៃ ! លោក អ្នក |
| ចូរដឹងគ្រប់គ្នាឲ្យច្បាស់ជាក់ | កុំឲ្យទាមទាក់ជាប់នឹងវា ។ |
| វាកើតវាចាស់វាឈឺស្លាប់ | វាមិនដែលស្តាប់យើងបញ្ជា |
| វាតែងប្រែប្រួលរាល់វេលា | ទៅតាមរឿងវាជាធម្មតា ។ |
| យើងកុំស្រឡាញ់យើងកុំស្អប់ | ត្រូវប្រែត្រឡប់ឧបេក្ខា |
| ទោះបីរូបកាយឯងយ៉ាងណា | បេះលែងអាត្មាឲ្យសុខបាន ។ |
| បើកាយឯងចាស់ឯងឈឺធ្ងន់ | ចិត្តអញអត់ធន់មិនរំខាន |
| ទោះបីឯងស្លាប់អញរ៉ាប់បាន | ចិត្តសុខក្សេមក្សាន្តតាមព្រះធម៌។ |
| ជម្រុះអញ និង របស់អញ | ពីដួងចិត្តចេញចិត្តស្អាតល្អ |
| ក្ខីស្វាងត្រជាក់ស្ងប់បវរ | បានដល់ព្រះធម៌និព្វានហោង ៕ |

**ចាកកើត ស្លាប់ ឆ្នាំ ២០០៣**

# សាសនា

| | |
|---|---|
| លោកថា ព្រះសង្ឃកំពង់សត្វ | ពេលមានវិបត្តិមានទុក្ខភ័យ |
| ព្រះសង្ឃតែងតែជួយលកលៃ | កំចាត់ទុក្ខភ័យប្រជាជន ។ |
| ជួយគិតជួយប្រាប់ជួយនាំធ្វើ | ជួយសព្វសារពើជួយកែកុន |
| ទោះបីហេតុការណ៍មហាធ្ងន់ | ព្រះសង្ឃជួយគន់គិតកែបាន ។ |
| ហេតុនេះ ព្រះសង្ឃត្រូវដើរមុន | នាំប្រជាជនកុំបីខាន |
| សាងជាតិសាសនាឲ្យថ្កើងថ្កាន | រុងរឿងឡើងបានសាន្តសុខសព្វ ៕ |

**ចាកមហាសុបិន ១៦ប្រការ ឆ្នាំ ២០០៣**